# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ សិរិឆ្ន ហ៊ុន ប្រធាន ក២ កងទ័ពជើងគោក | សមាជិក |

ប្រការ ២ : គណៈករណីនេះមានភារកិច្ច :

-ពិនិត្យ ស្រាវជ្រាវ ស៊ើបអង្កេត រាល់សកម្មភាព កសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានជនល្មើសឈ្មោះ សោម ឯក ជាមេក្លោង ។

-ប្រមែប្រមូលឯកសារ វត្ថុតាងផ្សេងៗ ទាក់ទងដល់សកម្មភាពខាងលើ

-ធ្វើការប្រជុំបូកសរុប វាយតំលៃ រួចរាយការណ៍ពីលទ្ធផលជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីរាយការណ៍ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីពិនិត្យ និងមានវិធានការតាមការជាក់ស្តែង ។

ប្រការ ៣ : គណៈករណីនេះមានសិទ្ធិប្រើប្រាស់កងកំលាំងក្រោមឱវាទរបស់ខ្លួន ដើម្បីបំពេញភារកិច្ចខាងលើតាមការចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៤
- -ឯកសារ-កាលប្បវត្តិ